# រឿង មហាចោរនៅទល់ដែន

## ភាគទី៧៩ (ជោគជ័យ)

នាងមាលាកំពុងឱបប្រយ័ត្នប្រតោងនាងទេវី។ ស្រីជាទាសីត្រូវព្រួញនិលឯកផាំងដួលខ្លោក។ មានន្ទរត់ហោទៅត្រកងបីស្រីឆ្នើមដែលនិយាយតិចៗថា:

ប្អូនសូមលា! ស្តាយណាស់...ការបដិវត្តន៍យើងមិនទាន់ចប់...

មានន្ទមុខស្រងូតឆ្លើយថា:

កូនចៅយើងមុខជាបានឃើញមិនខាន។

នាងមាលាញញឹមងក់ក្បាលបន្តិច រួចទន់ខ្លួនស្រិបមួយរំពេច។ មានន្ទក្រោករត់ទៅចាប់ដៃ "មនុស្សឥតឈ្មោះ" ដែលបានជួយនាងទេវីកាលនៅបាត់ដំបងបញ្ជូនទៅកៀនមួយសួរយ៉ាងប្រញាប់ថា:

លោកគ្រូ! ម៉េចបានទ័ពរបស់រាជរដ្ឋាភិបាលទេ?

បាន! កំពុងតតាំងគ្នាហ្នឹងហើយ

អុស! ជយោលោកគ្រូ! ខ្ញុំស្មានតែទ័ពរបស់បងកាល។

ទេ! ទេ! ទ័ពនេះ មកពីរាជធានីឧត្តុង្គមានជ័យណ៎ា

អ្នកណានាំមក?

ខ្ញុំ

ជយោ! លោកគ្រូ! ប៉ុន្មាននាក់?

ប្រាំពាន់

ជយោ! លោកគ្រូ! មានសំបុត្រទេ?

មាន

ថាយ៉ាងម៉េចខ្លះ?

ចាំមើលជាក្រោយ! ឥឡូវវាយទៅឲ្យអស់ដៃ។

អត្ថបទដោយ៖ មាស សុភាព

មានន្ទស្រែកបញ្ជាថា:

វាយ! អាកូន! ចូលលុក!

មានន្ទបង្វិលខ្លួនទៅជិតមហាកាលសួរថា:

បានមាសទេ?

បានស្រេច លោកគ្រូ!

ជយោ! យើងអាចច្បាំងម្ដេចឆ្នាំទៀត! ចូលអាកូន!

ឥឡូវនៅឯណាមាសនោះ?

យកទៅដល់កន្ទែងហើយ!

ការប្រឡូកប្រកាប់ប្រចាក់ក៏កើតមានយ៉ាងសាហាវៗ គេឮសូរតែដាវដែលទង្គិចគ្នា និងសម្រែកក្មេងចាស់ដែលភ័យផ្អើល។ មានន្ទវាយថយទៅជិត"លោកគ្រូឥតឈ្មោះ" ថា:

លោកគ្រូ! ធ្វើយ៉ាងម៉េចចាប់ឪពុកខ្ញុំបានណា?

បាទ!

រីឯកាមា ដល់ឃើញពលរេហ៍ខាងខ្លួនមានចំនួនតិចជាងក៏វាយថយខ្ទប់ទ្វារជាប់ រត់ទៅចាប់សេះមួយបំផាយរឹងទៅទិសខាងលិច។ គឺចំលើផ្លូវទៅក្រុង"អយុធ្យា"។ មានន្ទរត់ស្កាត់ដោយបានផ្ទោះទៅតាមបង្អួច។ កាមាទើបបានចម្ងាយប្រមាណដប់ម៉ែត្រ។ យកធ្នូបាញ់ម៉ាំងព្រួញហោះឆាល់ទៅត្រូវខ្នងកាមាពឹប តែសេះផាយយ៉ាងលឿនទៅទៀត។ កាមាដួលខ្ពបឱបខ្នងសេះ រួចមិនយូរប៉ុន្មានបុរសក៏ធ្លាក់ដាំដូងពីខ្នងអាជានេយ្យ។

ពលរេហ៍កាលបើអស់មេបញ្ជាក៏រត់ខ្ចាត់ខ្ចាយ។ តែពួកកងពលខាងយើងអត់ឲ្យរត់រួចឡើយ នាំគ្នាដេញតាមវាយប្រហារយ៉ាងឃោរឃៅ។ ក្រឡេកមើលទៅខាងត្បូង មានន្ទឃើញសេះសមួយបោលទៅឆ្ងាយៗ លើអស្សពាហ៍ បុរសស្គាល់ជាក់ជានាងទេវី ភរិយាសម្ងាញ់តែមួយដែលប្រាកដជាអាក់អន់ចិត្តរត់ចោលអ្នកវិញៗ មាណពចាប់បានសេះមួយបំផាយតាមឥតបង្អង់ឡើយ។ លឿនប្រិចៗ សេះមានន្ទកាន់តែជិតសេះស្រីវរលក្ខណ៍ឡើងជិតឡើងៗ លុះ

ដល់កណ្ដាលវាលជិតដើមពោធិ៍ ដែលកាលប្រាំឆ្នាំមុន បានប្រកាប់គ្នាជាមួយកាមា បុរសលោតផ្លោតទៅចាប់នាងទេវីដែលដួលទៅនឹងដី។ នៅពីក្រោមស្វាមី ស្រីបម្រះយ៉ាងអស់ទំហឹង តែមាននទ្ទសង្កត់ជាប់។ មួយស្របក់ធំ កម្លាំងនាងទេវីក៏ល្អក់អស់ ហេវញើសចេញពេញមុខ។ ស្រីធ្មេចភ្នែក ដើម្បីកុំអោយឃើញមុខប្រុសកំណាច ដែលនាងស្រលាញ់យូរណាស់មកហើយ។ ដែលជាហេតុនៃកងទុក្ខរបស់នាងនេះ។

មាននទ្ទឱបរឹតស្រីដែលគេចមុខចុះឡើងលើធរណី ដើម្បីកុំអោយស្វាមីដែលទើបចង់សម្លាប់ថ្មីៗនេះដាក់ច្រមុះជិតនាងបាន។

មាននទ្ទប្ដេជ្ញាថា ដរាបណាប្អូនទេវីសម្លាញ់ចិត្តិនទាន់អស់ខឹងទេដរាបនោះ អ្នកមិនលែងសង្កត់នាងឡើយ។

ជនទាំងពីរឥតនិយាយអ្វីឡើយ រង់ចាំតែកាយវិការប៉ុណ្ណោះឯង លែងសម្ដែងទឹកចិត្តរៀងៗខ្លួន។ នាងទេវីទន់អស់ដៃជើង ប្រឹងបម្រះទៅទៀតលែងរួចឡើយ គឺនៅតែក្បាលដែលរេចុះឡើងលើស្មៅខ្ចី។ យូរមកសេចក្ដីរលឹកប្ដី សេចក្ដីស្នេហា សេចក្ដីគោរព បើកទ្វារក្នុងដួងចិត្តជីតាបន្តិចម្ដងៗ។

ទ្វារកាមគុណនេះ ធ្វើឲ្យទឹកភ្នែកស្រីហូរជាថ្មី នេត្រាកំសត់នេះក៏មើលចំនេត្រាស្វាមី។ នាងឃើញរូបនាងនៅក្នុងកែវភ្នែកប្ដីកំសត់នេះ ដែលអង្វរសូមទោសនាងហើយ។ សេចក្ដីអាណិតចូលមកបន្ថែមលើកម្លាំងស្នេហាទៀត ដៃស្ត្រីក៏រួមៗឱបសង្សារកាន់តែតឹងឡើងៗ។

មាននទ្ទខ្សឹបដាក់ត្រចៀកនាង សួរថា:

កូនយើងនៅឯណា?

នៅភូមិថ្មី ផ្ទះយាយម៉ាវ៉ា

អូនឯងមកនៅផ្ទះដែលមណីស្លាប់ ប៉ុន្មានថ្ងៃហើយ?

ពីរថ្ងៃ

អូនមកជាមួយអ្នកណា?

អត្ថបទដោយ៖ មាស សុភាព

ជាមួយទាហាន

គេចាប់ឬ?

ចាំះ! ពីមុនខ្ញុំនៅបាត់ដំបង តាម្នាក់ជួយខ្ញុំ យកខ្ញុំមកនៅភូមិថ្មី។ ពីរថ្ងៃមុននេះ មានទាហានទៅព័ទ្ធចាប់ខ្ញុំមក។

មានន្ទអោបរឹងថើបស្រីយ៉ាងខ្លាំង ដែលនិយាយទៅទៀតលែងរួច។

នៅឯសមរភូមិ សូរត្រែបញ្ឈប់សង្គ្រាមក៏លាន់ឮឡើង។

មានន្ទលើកស្រីអោយក្រោកឈរ។ អ្នកបីបមធីតាដាក់លើខ្នងសេះ រួចឱបស្រី បញ្ជិះទៅឯទ័ពឯភូមិវិញ។

មាហាកាល អារុណ លោកគ្រូឥតឈ្មោះ វីរៈ នាយកត បញ្ជាឲ្យទាហានឈរជាជួររង់ចាំធ្វើគារវកិច្ចចំពោះមេទ័ពយើង។

មហាជនរាប់ពាន់នាក់ ឈរត្រៀបត្រាស្រែក"ជយោ! មានន្ទ! ជយោ! មានន្ទ! ជយោ! ឯករាជ្យ! ជយោ! ឯករាជ្យ!"

មានន្ទ និងទេវី លើកដៃគ្រវីជាសញ្ញាតបអំណរគុណវិញ ដោយងាកមើលមុខគ្នាទៅវិញទៅមកយ៉ាងញឹកញយបំផុត។

(ចប់ដោយបរិបូណ៌)

អត្ថបទដោយ៖ មាស សុភាព